## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អាជ្ញាធរទន្លេសាប

# ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២១
# អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

រៀបចំដោយ ៖ អាជ្ញាធរទន្លេសាប
សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
ខែកុម្ភៈ ឆ្នាំ ២០២១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**

លេខ :....០១១.......អទស

ថ្ងៃ ពុធ ១៣ កើត ខែ ផល្គុន ឆ្នាំជូតទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ គ.ស. ២០២១

**ជម្រាបមក**

**ឯកឧត្តម លោកទីប្រឹក្សា លោកប្រធាននាយកដ្ឋានក្រោមឱវាទ**

**អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

**កម្មវត្ថុ ៖** ការដាក់ឲ្យអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២១ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

**ជូនភ្ជាប់ ៖** ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២១ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋាន ជ្រាបថា ៖ ក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយចីរភាព ។

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២១ ដើម្បីជម្រុញប្រសិទ្ធភាពការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាបឆ្នាំ ២០២១-២០២៥ ឲ្យទទួលបានជោគជ័យ និងបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃ អំពីសក្តានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ស្របតាមអាណត្តិការងារសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកទីប្រឹក្សា និងលោកប្រធាននាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប អនុវត្តន៍ឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

# មាតិកា


**បុព្វកថា** ...... 1

**ផ្នែកទី១ សេចក្តីផ្តើម** ...... 3

១.១- សាវតារ ...... 3

១.២- អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ...... 3

១.៣- ដំណើរការរៀបចំផែនការសកម្មភាព ...... 5

ដ្យាក្រាមទី១ ដំណើរការរៀបចំផែនការសកម្មភាព ...... 7

១.៤- អំពីទម្រង់នៃការរៀបចំផែនការសកម្មភាព ...... 8

**ផ្នែកទី២ សមិទ្ធផល និងបញ្ហាប្រឈមនៃផែនការយុទ្ធសាស្ត្រ ២០១៦-២០២០** ...... 9

២.១- សមិទ្ធផល ...... 9

២.២- បញ្ហាប្រឈម ...... 17

**ផ្នែកទី៣ អំពីផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥** ...... 19

ដ្យាក្រាមទី២ គំនូសបំព្រួញរចនាសម្ព័ន្ធនៃចក្ខុវិស័យ បេសកកម្ម និងសសរស្តម្ភ ...... 19

៣.១- ចក្ខុវិស័យ និងបេសកកម្ម ...... 20

៣.២- គោលដៅយុទ្ធសាស្ត្រ និងគោលបំណង ...... 20

៣.៣- បាវចនា និងរចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប ...... 20

ដ្យាក្រាមទី៣ រចនាសម្ព័ន្ធអាជ្ញាធរទន្លេសាប ...... 21

៣.៤- ទិសដៅយុទ្ធសាស្ត្រ ...... 22

៣.៥- សកម្មភាពយុទ្ធសាស្ត្រ ...... 22

**ផ្នែកទី៤ ផែនការសកម្មភាពរបស់អាជ្ញាធរទន្លេសាប ២០២១** ...... 25

៤.១- សេចក្តីផ្តើម ...... 25

៤.២- សកម្មភាពការងារឆ្នាំ ២០២១ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ...... 25

៤.៣- តារាងទី ១៖ ម៉ាទ្រិកផែនការសកម្មភាពឆ្នាំ ២០២១ អគ្គលេខាធិការដ្ឋាន អ.ទ.ស ...... 31

**ផ្នែកទី៥ យន្តការអនុវត្ត និងប្រភពថវិកា ធនធានហិរញ្ញវត្ថុ** ...... 57

៥.១- យន្តការសម្រាប់អនុវត្ត ...... 57

៥.២- ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ ...... 57

តារាងទី២៖ ការប៉ាន់ប្រមាណថវិកាសម្រាប់សកម្មភាពឆ្នាំ ២០២១ ...... 58

**ផ្នែកទី៦ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្តីសន្និដ្ឋាន** ...... 59

៦.១- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ...... 59

៦.២- សេចក្តីសន្និដ្ឋាន ...... 59

**ឧបសម្ព័ន្ធ** ....................................................................................................................61
ឧបសម្ព័ន្ធទី១ តារាងម៉ាទ្រិកផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ របស់អាជ្ញាធរទន្លេសាប ........61
ឧបសម្ព័ន្ធទី២ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប .... 65
ឧបសម្ព័ន្ធទី៣ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ស្តីពីការកែសម្រួល មាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៨ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/ ៧០៥ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប.................................72
ឧបសម្ព័ន្ធទី៤ អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ..................................................... 77
ឧបសម្ព័ន្ធទី៥ ប្រកាសលេខ ០២៥ អ.ទ.ស ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ....... 82
ឧបសម្ព័ន្ធទី៦ អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹក ចំនួន ៦៤៧.៤០៦ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប.................... 89

# បុព្វកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃប្រទេសកម្ពុជា មានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប គឺជាប្រព័ន្ធផ្លូវទឹកទំនាក់ទំនងយ៉ាងសំខាន់បំផុត ដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ បឹងទន្លេសាប ស្រូបយកទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយកម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិ ចាក់បំពេញវាលទំនាបលិចទឹកនៃតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលជាជម្រក និងបង្កបានជាចំណី សម្រាប់ជីវចម្រុះយ៉ាងសម្បូរបែប មានពពួកមច្ឆជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ក្រៅពីតួនាទីជាបឹង ទទួលយកទឹក និងជួយកាត់បន្ថយគ្រោះទឹកជំនន់ពីទន្លេមេគង្គ វាក៏ជាប្រភពសន្តិសុខស្បៀង ជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងជួយទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានប្រទេសជាតិទាំងមូល ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ និងកំណើនប្រជាពលរដ្ឋ បានធ្វើឲ្យមានហានិភ័យនៃបឹងទន្លេសាប បាននិងកំពុងទទួលរងនូវការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់សុខមាលភាពបឹង បរិស្ថាន ជីវចម្រុះ និងធនធានធម្មជាតិ ដូចជា ៖ ការប្រើប្រាស់បច្ចេកវិជ្ជាទំនើប បច្ចេកវិជ្ជាកែច្នៃ ការកាប់បំផ្លាញ រុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានជលផល បម្រែបម្រួលអាកាសធាតុ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់ទំនប់វារីអគ្គិសនីនៅផ្នែកខាងលើជាដើម ។

ដោយមើលឃើញពីសារៈសំខាន់នៃបឹងទន្លេសាប និងដើម្បីចូលរួមចំណែកក្នុងកិច្ចការការពារធនធានធម្មជាតិ និងជីវចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានដ៏កម្រនៅតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព ក៏ដូចជាការចូលរួមពង្រឹងប្រសិទ្ធភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា **អាជ្ញាធរទន្លេសាប** បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២១ ដែលជាផែនការសកម្មភាពនៃឆ្នាំទី៨(ជារួម) និងជាផែនការសកម្មភាពឆ្នាំទី១ នៃផែនការយុទ្ធសាស្ត្រលើកទី២ (២០២១-២០២៥) របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប បន្តពីការអនុវត្តផែនការយុទ្ធសាស្ត្រលើកទី១(២០១៦-២០២០) ។

ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២១ គឺជាសកម្មភាពការងារលម្អិត ក្នុងការប្រតិបត្តិការងារប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប រួមជាមួយការចូលរួមសហការពីបណ្តាក្រសួងស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញ ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២១-២០២៥ ឲ្យទទួលបានជោគជ័យ ។ ជាមួយខ្លឹមសារផែនការសកម្មភាពការងារនេះ ក៏ត្រូវបានរៀបចំបន្ស៊ីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២១-២០២៥ ។

ជាពិសេស ស្របតាមតួនាទី ភារកិច្ចការងារ ដែលបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងាររបស់អាជ្ញាធរទន្លេសាបក្នុងការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

ផែនការសកម្មភាពការងារនេះ ចែកជា ៦ ផ្នែកសំខាន់ៗគឺ ៖

- ផ្នែកទី១ សេចក្តីផ្តើម ដែលរៀបរាប់អំពី សាវតារ អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ដំណើរការរៀបចំ និងទម្រង់។
- ផ្នែកទី២ រំលឹកអំពីសមិទ្ធផល និងបញ្ហាប្រឈមនៃផែនការយុទ្ធសាស្ត្រ(២០១៦-២០២០)
- ផ្នែកទី៣អំពីផែនការយុទ្ធសាស្ត្រ(២០២១-២០២៥)
- ផ្នែកទី៤ ផែនការសកម្មភាពឆ្នាំ២០២១របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- ផ្នែកទី៥ យន្តការអនុវត្ត និងប្រភពថវិកា ធនធានហិរញ្ញវត្ថុ
- ផ្នែកទី៦ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងសេចក្តីសន្និដ្ឋាន

ជាក់ស្តែង ផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២១ នេះ នឹងប្រើប្រាស់ធ្វើជាឧបករណ៍ជួយតម្រង់ទិសការងារអគ្គលេខាធិការដ្ឋាន នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប សម្រាប់យកទៅអនុវត្តន៍ឲ្យមានប្រសិទ្ធភាព ហើយក៏ជាទស្សនទានដ៏សំខាន់មួយសម្រាប់ផ្តល់ជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគិតគូរពិចារណាធ្វើការវិភាជន៍ថវិកាប្រចាំឆ្នាំ និងដៃគូអភិវឌ្ឍន៍នានា ដែលមានគោលបំណងចូលរួមសហការ និងគាំទ្រទាំងផ្នែកថវិកា បច្ចេកទេស និងធនធានមនុស្ស ដល់ដំណើរការការងាររបស់អាជ្ញាធរទន្លេសាប ។

# ផ្នែកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

ដើម្បីធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសម្រាប់រក្សាទុកជាកេរ្តិ៍មរតកដ៏ប្រពៃរបស់មនុស្សជាតិយូរអង្វែង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបង្កើតស្ថាប័នថ្មីមួយស្ថិតក្រោមការគ្រប់គ្រងនៃ**ទីស្តីការគណៈរដ្ឋមន្ត្រី** និងជាសេនាធិការផ្ទាល់បន្ថែមជួយដល់រាជរដ្ឋាភិបាលគឺ **អាជ្ញាធរអាងទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧។ យោងលើការពិនិត្យជាក់ស្តែងរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ឡើងវិញលើរចនាសម្ព័ន្ធនៃការគ្រប់គ្រង និងតួនាទីភារកិច្ច ក៏ដូចជាដែនសមត្ថកិច្ចវិសាលភាពនៃការគ្រប់គ្រងរបស់អាជ្ញាធរអាងទន្លេសាប មកជា **អាជ្ញាធរទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ ស្តីពីការបង្កើត អាជ្ញាធរទន្លេសាប។

## ១.២. អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ត្រូវដើរតួនាទីយ៉ាងសំខាន់ ជាពិសេសអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ត្រូវយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លាបំផុត ចំពោះការអនុវត្តផែនការសកម្មភាពការងារឆ្នាំ ២០២១ ស្របទៅតាមចំណុចអាទិភាពចម្បងដូចខាងក្រោម៖

- កៀរគរបង្កើនធនធានហិរញ្ញវត្ថុដើម្បីបង្កលទ្ធភាពដល់ការចុះសិក្សាស្រាវជ្រាវជាមូលដ្ឋានឲ្យបានពេញលេញស្របតាមមុខងាររបស់ស្ថាប័ន/អង្គភាពប្រចាំថ្ងៃ
- បន្តពង្រឹងពង្រីកលើការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍លើការចែករំលែក និងផ្សព្វផ្សាយ អំពីដំណើរការអនុវត្តសកម្មភាព បច្ចេកទេសដែលជាមូលដ្ឋានគ្រឹះរួមមាន៖
  - ពង្រឹងពង្រីកការពិគ្រោះយោបល់ ការចែករំលែក និងផ្សព្វផ្សាយពីបច្ចេកទេសនៃការសិក្សាស្រាវជ្រាវ លទ្ធផលរបកគំហើញពាក់ព័ន្ធនឹងសក្តានុពល និងផលប៉ះពាល់ផ្សេងៗនៃតំបន់បឹងទន្លេសាប ជំរុញសកម្មភាពអាជ្ញាធរទន្លេសាប ឲ្យដើរតួនាទីជាអង្គភាពថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការចែករំលែក និងផ្សព្វផ្សាយព័ត៌មានទិន្នន័យដល់ភាគីពាក់ព័ន្ធ
  - រៀបចំ និងផ្សព្វផ្សាយពីរបាយការណ៍ ស្តីពីស្ថានភាពតំបន់បឹងទន្លេសាប
  - រៀបចំ និងផ្សព្វផ្សាយពីគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព

- រៀបចំ និងផ្សព្វផ្សាយពីផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបប្រកបដោយចីរភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិឲ្យកាន់តែស៊ីជម្រៅ

- ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព័ត៌មានវិទ្យាសាស្ត្រតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ជំរុញក្រុមការងារ/ជំនាញផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងការគ្រប់គ្រងគម្រោងរួមជាមួយមន្ត្រីរាជការបម្រើការងារនៅអាជ្ញាធរទន្លេសាបដែលមានជំនាញពាក់ព័ន្ធផ្សេងៗ ដើម្បីជួយដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រឲ្យសម្រេចបានជោគជ័យ
- លើកកម្ពស់ភាពជាដៃគូ រួមទាំងដៃគូបច្ចេកទេស ធនធានមនុស្ស និងហិរញ្ញវត្ថុ។

## ១.៣ ដំណើរការរៀបចំផែនការសកម្មភាពឆ្នាំ២០២១

យោងលើផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបឆ្នាំ ២០២១-២០២៥ ដែលបានអនុម័តដោយ **ឯកឧត្តមប្រធាន** អាជ្ញាធរទន្លេសាប កាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ដែលអគ្គលេខាធិការដ្ឋាន ជាអ្នករៀបចំ អនុវត្តន៍ គ្រប់គ្រង និងដឹកនាំផែនការយុទ្ធសាស្ត្រនេះ ដោយមាននាយកដ្ឋានជំនាញទាំង៤ ជាអ្នកទទួលខុសត្រូវលើការអនុវត្តន៍សកម្មភាពរៀងៗខ្លួនតាមជំនាញ។ នាយកដ្ឋានជំនាញ ត្រូវលើកសំណើដើម្បីអនុវត្តន៍ផែនការសកម្មភាពប្រចាំឆ្នាំដោយផ្អែកលើ សកម្មភាពយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រនេះ និងដោយអនុលោមតាមតួនាទី ភារកិច្ចរបស់នាយកដ្ឋាននីមួយៗដែលមានចែងក្នុងអនុក្រឹត្យ លេខ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប។ សមាសភាពក្រុមរៀបចំ ផែនការសកម្មភាពរួមមាន៖ អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីការិយាល័យផែនការ និងសហប្រតិបត្តិការ នៃនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ។ ដំណើរការរៀបចំផែនការសកម្មភាពឆ្នាំ២០២១ ប្រព្រឹត្តទៅ តាម ៣ ដំណាក់កាលដូចខាងក្រោម៖

| ដំណាក់កាល | សកម្មភាព |
|---|---|
| ដំណាក់កាលទី ១ | ១.នាយកដ្ឋានទាំង៤ ត្រូវកសាងសកម្មភាពដែលត្រូវអនុវត្តក្នុងឆ្នាំ២០២១ ដោយមានការសម្របសម្រួលពី ឯកឧត្តមអគ្គលេខាធិការរង តាមនាយកដ្ឋានជំនាញរៀងៗខ្លួន លើកលែងតែនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ដែលសម្របសម្រួលដោយ ឯកឧត្តមអគ្គលេខាធិការ។ |
| | ២. សំណើសកម្មភាពត្រូវបានបង្ហាញក្នុងអង្គប្រជុំដែលដឹកនាំ **ដោយ ឯកឧត្តម ម៉ៅ ហាក់** សមាសភាពចូលរួមថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក្រុមការងារទីប្រឹក្សា និងនាយកដ្ឋានជំនាញទាំង៤ |
| | ៣. បច្ចុប្បន្នភាពសកម្មភាព និងកែសម្រួលសកម្មភាព នឹងត្រូវផ្ញើត្រឡប់មកអគ្គលេខាធិការដ្ឋានតាមរយៈក្រុមការងារ |
| ដំណាក់កាលទី ២ | ១. កិច្ចប្រជុំកម្រិតបច្ចេកទេស៖ ដែលដឹកនាំដោយ **ឯកឧត្តម លឹម ពុយ** សមាសភាពចូលរួមថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក្រុមការងារ ទីប្រឹក្សា និងនាយកដ្ឋានជំនាញទាំង៤ |
| | ២. កិច្ចប្រជុំកម្រិតបច្ចេកទេស៖ ដែលដឹកនាំដោយ **ឯកឧត្តម លឹម ពុយ** សមាភាពចូលរួម ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នាយកដ្ឋាន ត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស និងនាយកដ្ឋាន ធនធានធម្មជាតិ |
| | ៣. កិច្ចប្រជុំ ដែលដឹកនាំដោយ ឯកឧត្តម អគ្គលេខាធិការ សមាភាពចូលរួម នាយកដ្ឋាន រដ្ឋបាលផែនការ និងសហប្រតិបត្តិការ |
| | ៤. ក្រុមការងាររៀបចំដាក់ ជូន **ឯកឧត្តមប្រធាន** ដើម្បីសុំគោលការណ៍សកម្មភាព ដាក់បញ្ចូលក្នុង ផែនការសកម្មភាពការងារឆ្នាំ ២០២១ របស់ អគ្គ |

| | |
|---|---|
| | លេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប |
| | ៥. កិច្ចប្រជុំពិនិត្យសេចក្ដីព្រាងចុងក្រោយ ដែលដឹកនាំដោយ **ឯកឧត្ដម ម៉ៅ ហាក់** សមាសភាពចូលរួមអនុប្រធាន អទស ថ្នាក់អគ្គលេខាធិការដ្ឋាន ថ្នាក់នាយកដ្ឋាន ថ្នាក់ការិយាល័យពាក់ព័ន្ធ និងមន្ត្រីពាក់ព័ន្ធ |
| | ៦. រៀបចំចងក្រងផែនការសកម្មភាពការងារទៅតាមស្មាតីកិច្ចប្រជុំ និងដាក់ជូនឯកឧត្ដមប្រធាន អាជ្ញាធរទន្លេសាបចុះហត្ថលេខាជាផ្លូវការ |
| ដំណាក់កាលទី ៣ | ១. អគ្គលេខាធិការដ្ឋានរៀបចំបោះពុម្ពសៀវភៅស្ដីពី ផែនការសកម្មភាពការងារឆ្នាំ ២០២១ ជាភាសាខ្មែរ និងភាសាអង់គ្លេស និងចែកជូនអ្នកពាក់ព័ន្ធ |



១.ដំណាក់កាល ជ្រើសរើសសកម្មភាព
២.ដំណាក់កាល រៀបចំសេចក្តីព្រាងផែនការសកម្មភាព
៣.ដំណាក់កាល បោះពុម្ព ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត
ដំណាក់កាលទី ១
ការកសាងសកម្មភាពថ្នាក់អគ្គលេខាធិការដ្ឋានសម្របសម្រួល ជាមួយនាយកដ្ឋានជំនាញទាំង ៤
ដំណាក់កាលទី ១
សំណើសកម្មភាពត្រូវបានបង្ហាញ
កិច្ចប្រជុំ៖
១.ផ្សព្វផ្សាយ ផ.យ.ស អ.ទ.ស ២០២១-២០២៥
២.ពិនិត្យវឌ្ឍនភាពការងារអនុវត្តន៍ផែនការសកម្មភាពឆ្នាំ២០២០ អ.ទ.ស និងលើកទិសដៅ២០២១
៣.ដំណើរការកសាងផែនការសកម្មភាព ២០២១ ដឹកនាំដោយ ឯកឧត្តម ម៉ៅ ហាក់
ដំណាក់កាលទី ១
បច្ចុប្បន្នភាពសកម្មភាព សកម្មភាពទាំងអស់ត្រូវផ្ញើត្រឡប់មកក្រុមការងារ
ដំណាក់កាលទី ២
ប្រជុំកម្រិតបច្ចេកទេស ដឹកនាំដោយ ឯកឧត្តម លឹម ពុយ ចូលរួមដោយ ក្រុមការងារ ទីប្រឹក្សា និងនាយក ដ្ឋានទាំង៤
ដំណាក់កាលទី ២
កិច្ចប្រជុំ ដឹកនាំដោយ ឯកឧត្តម លឹមពុយ ចូលរួមដោយ ថ្នាក់អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានបច្ចេកទេស ទាំង២
ដំណាក់កាលទី ២
កិច្ចប្រជុំដឹកនាំដោយ ឯកឧត្តម អគ្គលេខាធិការ ចូលរួមដោយ នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ
ដំណាក់កាលទី ២
ប្រជុំកម្រិតថ្នាក់ដឹកនាំដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងចុងក្រោយ ដឹកនាំដោយ ឯកឧត្តម ម៉ៅ ហាក់ ចូលរួមដោយឯកឧត្តមអនុប្រធានទាំង២ អគ្គលេខាធិការ និងអគ្គលេខាធិការរងទាំងពីរ ទីប្រឹក្សា ជំនួយការ នាយកដ្ឋានទាំង៤និង មន្ត្រីការិ.ផែនការ និងសហប្រតិបត្តិការ
ដំណាក់កាលទី ២
រៀបចំចងក្រងផែនការសកម្មភាពសប្តាហ៍ទី២ ខែកុម្ភៈ ក្រុមការងាររៀបចំចងក្រងផែនការសកម្មភាព តាមស្មារតីកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំដើម្បីពិនិត្យ និងអនុម័ត សេចក្តីព្រាងចុងក្រោយ
សប្តាហ៍ទី២ ខែកុម្ភៈ ២០២១
ការកសាងសកម្មភាពថ្នាក់អគ្គលេខាធិការសម្របសម្រួលជាមួយនាយកដ្ឋានជំនាញទាំង៤

## ១.៤. អំពីទម្រង់ នៃការរៀបចំផែនការសកម្មភាពការងារ

ខ្លឹមសារផែនការសកម្មភាពនេះត្រូវបានរៀបចំតាមលំដាប់លំដោយដូចជាបុព្វកថា ខ្លឹមសារសង្ខេប និងបែងចែកជា៦ ផ្នែក រួមមានជាអាទិ៍៖

១. ផ្នែកទី១ គឺសេចក្តីផ្តើម ដែលបានរំលេចអំពីសាវតារ អាទិភាពសម្រាប់អាជ្ញាធរទន្លេសាប ដំណើរការនៃការរៀបចំ និងទម្រង់នៃផែនការសកម្មភាពការងារ

២. ផ្នែកទី២ បង្ហាញពីសមិទ្ធផលដែលអាជ្ញាធរទន្លេសាបសម្រេចបានក្នុងផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ បញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួនដែលបានជួបប្រទះ

៣. ផ្នែកទី៣ បង្ហាញពីផែនការយុទ្ធសាស្ត្រ២០២១-២០២៥ ដែលរំលេចចំណុចមួយចំនួនដូចជា ចក្ខុវិស័យ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ គោលបំណងទិសដៅយុទ្ធសាស្ត្រ និងសកម្មភាពយុទ្ធសាស្ត្រ

៤. ផ្នែកទី៤ បង្ហាញពីសកម្មភាពការងាររបស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

៥. ផ្នែកទី៥ បង្ហាញពីយន្តការអនុវត្តដែលរំលេចពីអង្គភាពទទួលខុសត្រូវ និងរចនាសម្ព័ន្ធការងាររបស់អាជ្ញាធរទន្លេសាប ផែនការថវិកា និងប្រភពធនធានផ្សេងៗសម្រាប់អនុវត្តន៍

៦. ផ្នែកទី៦ គឺជាផ្នែកចុងក្រោយដែលបង្ហាញពីយន្តការនៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដែលនឹងរំលេចពីការត្រួតពិនិត្យតាមដាននិងវាយតម្លៃប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស និងសេចក្តីសន្និដ្ឋានជារួមសម្រាប់ផែនការសកម្មភាពការងារនេះ។ ក្រៅពីផ្នែកសំខាន់ទាំង៦ ផែនការសកម្មភាពនេះមានភ្ជាប់ឧបសម្ព័ន្ធ ដែលជាឯកសារយោង និងបញ្ជាក់នូវខ្លឹមសារលម្អិតដែលមានការពាក់ព័ន្ធ។

# ផ្នែកទី២

# សមិទ្ធផល និងបញ្ហាប្រឈមការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៦-២០២០

សម្រាប់រយៈពេល៥ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០១៦-២០២០ បានទទួលនូវសមិទ្ធផល បញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួនរួមមាន៖

## ២.១- សមិទ្ធផល

ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០១៦-២០២០ ជាឯកសារផែនការយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវដែលបានកំណត់ច្បាស់អំពីបេសកកម្មការងារ និងទិសដៅដើម្បីពង្រឹងប្រសិទ្ធភាពការងារជាមួយគោលបំណងជាលទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាពរបស់អាជ្ញាធរទន្លេសាបសម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ និងឆ្លុះបញ្ចាំងពីការចូលរួមលើកកម្ពស់គោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំដៅរួមចំណែកដល់ការរក្សាឲ្យបាននូវតុល្យភាពនៃការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ការកំណត់បេសកកម្មការងាររយៈពេល៥ឆ្នាំ ក្នុងការឈានទៅសម្រេចបាននូវចក្ខុវិស័យ "ធ្វើឲ្យអាជ្ញាធរទន្លេសាបជាស្ថាប័ន/អង្គភាពគំរូមួយ ដែលអាចសម្រេចបានជោគជ័យក្នុងការសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់បឹងទន្លេសាប"។ អាជ្ញាធរទន្លេសាបទទួលបានសមិទ្ធផលដែលកំណត់ទិសដៅជាយុទ្ធសាស្ត្រចំនួន៥ រួមជាមួយចង្កោមសកម្មភាពមានដូចខាងក្រោម ៖

### ទិសដៅទី១ ពង្រឹងគោលនយោបាយ បទប្បញ្ញត្តិ និងក្របខណ្ឌស្ថាប័ន

ឈរលើស្មារតីសម្របសម្រួល ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នបច្ចេកទេស និងដៃគូពាក់ព័ន្ធក្នុងការយកចិត្តទុកដាក់ចែករំលែកព័ត៌មាន/ទិន្នន័យ ផ្សព្វផ្សាយគោលនយោបាយ និងបទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាលដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដល់ភាគីពាក់ព័ន្ធទាំងនៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធនៅក្នុងតំបន់បឹងទន្លេសាបរួមជាមួយការផ្សព្វផ្សាយការយល់ដឹងអំពីក្របខណ្ឌច្បាប់ និងគោលនយោបាយសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានទឹក និងបរិស្ថានធនធានធម្មជាតិក្នុងគោលបំណងសំដៅដល់កិច្ចការពារ និងទប់ស្កាត់ផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាននៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធដូចជា ៖

- ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអមដោយបទប្បញ្ញត្តិអនុក្រឹត្យពាក់ព័ន្ធសំខាន់ៗមួយចំនួនទៀតក្នុងកិច្ចការពារ និងគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព

រួមមានៈ នីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទីភារកិច្ចរបស់សហគមន៍កសិករប្រើប្រាស់ទឹក និងការគ្រប់គ្រងអាងទន្លេ

- ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ច្បាប់ស្តីពី ជលផល និងច្បាប់ស្តីពី ព្រៃឈើ
- ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ។

ជំរុញការខិតខំប្រឹងប្រែង និងសិក្សាស្វែងយល់ពីខ្លឹមសារនៃច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធនីមួយៗ ដែលមានស្រាប់ដើម្បីធ្វើជាមូលដ្ឋានចំណេះដឹងបន្តពង្រឹងសកម្មភាពការងារស្នូលរបស់អង្គភាព និងរៀបចំចងក្រងឲ្យទៅជាសូចនាករសំខាន់ៗសម្រាប់កសាងឯកសារបច្ចេកទេស និងប្រើប្រាស់ជាជំនួយដល់ការសិក្សាស្វែងយល់ និងស្រាវជ្រាវចងក្រងព័ត៌មាន និងទិន្នន័យបន្ថែម។ បន្តការចែករំលែកផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទដែល បាន និងកំពុងបម្រើការងារតាមជំនាញរួមជាមួយអ្នកពាក់ព័ន្ធ ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានតាមរយៈកិច្ចពិភាក្សា អង្គសិក្ខាសាលា សន្និសីទ វេទិកាផ្សេងៗ និងបណ្តាញចែករំលែកព័ត៌មានគេហទំព័រ ប្រព័ន្ធបណ្តាញសង្គម ទស្សនាវដ្តី សកម្មភាពការងារ និងគោលនយោបាយការងារ។ល។

ក្នុងស្មារតីយកចិត្តទុកដាក់លើការកំណត់ដែនវិសាលភាព (មាត្រា ២) បើទោះបីមិនទាន់ត្រូវបានបញ្ចប់នៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំលើកទី១ អាជ្ញាធរទន្លេសាបបានខិតខំប្រឹងប្រែងពង្រឹងការយល់ដឹងដោយស្វែងយល់លើឯកសារបច្ចេកទេស និងឯកសារច្បាប់ បទបញ្ញត្តិពាក់ព័ន្ធដែលមានស្រាប់ដើម្បីប្រមូលផ្តុំចងក្រងមកធ្វើជាទឡ្ហីករណ៍សម្រាប់ជាធាតុចូលដ៏សំខាន់ ដែលអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំបច្ចុប្បន្នភាពឯកសារបច្ចេកទេសបានច្បាស់លាស់ និងបានចុះសិក្សាប្រមូលនូវរាល់ទិន្នន័យសម្រាប់ធ្វើការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញតាមទីតាំងជាក់ស្តែង មុននឹងដាក់ស្នើសុំយោបល់ជូនថ្នាក់ដឹកនាំពិនិត្យ និងធ្វើសេចក្តីសម្រេចចិត្តរៀបចំបទប្បញ្ញត្តិក្នុងការកំណត់ដែនវិសាលភាពតំបន់បឹងទន្លេសាប។

ពង្រឹងការអនុវត្តតួនាទី ភារកិច្ច ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ តាមរយៈការចុះធ្វើអធិការកិច្ចជាប្រចាំក្នុងសកម្មភាពចូលរួមការពារដែនព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប (តំបន់៣) នៅតាមបណ្តាស្រុក ឃុំ និងភូមិពាក់ព័ន្ធជាប់តំបន់ព្រៃលិចទឹក ដែលស្ថិតនៅក្នុងដែនដីរដ្ឋបាលនៃខេត្តទាំង៦នៅជុំវិញតំបន់បឹងទន្លេសាប។ ក្នុងនោះក៏បានចុះផ្ទៀងផ្ទាត់រាល់និយាមកាទាំង៨០២ បង្គោល និងស្វែងយល់ស្រង់ព័ត៌មានទិន្នន័យបន្ថែម អំពីការបាត់បង់ព្រៃលិចទឹក និងការបាត់បង់បង្គោលព្រំប្រទល់ដែលបណ្តាលមកពីសកម្មភាពមនុស្ស និងបង្កមកពីបាតុភូតធម្មជាតិ។ តាមលទ្ធផលនៃការចុះសិក្សាជាក់ស្តែងបានបង្ហាញឲ្យឃើញថា ព្រៃលិចទឹកនៅជុំវិញតំបន់បឹងទន្លេសាបត្រូវបានទទួលរងនូវការទន្ទ្រានយ៉ាងធ្ងន់ធ្ងរ ហើយត្រូវបានបាត់បង់កើនពីមួយឆ្នាំទៅមួយឆ្នាំ។ ជាមួយនឹងការបាត់បង់ និងការកាប់ទន្ទ្រានព្រៃលិចទឹក អាជ្ញាធរទន្លេសាប បានចូលរួមលើកកម្ពស់នូវកិច្ចការការពារថែរក្សាព្រៃលិចទឹក តាមរយៈការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ព្រៃលិចទឹកវិធានការការពារព្រៃលិចទឹក ការដាំឡើងវិញ

និងការបណ្តុះឈើកូនព្រៃលិចទឹកជាមួយសហគមន៍មូលដ្ឋាន នៅតាមបណ្តាតំបន់ពាក់ព័ន្ធនៃខេត្តជុំវិញតំបន់បឹងទន្លេសាប។

ដើម្បីសម្រេចបានជោគជ័យនូវទិសដៅយុទ្ធសាស្ត្រទី១ ខាងលើនេះ អាជ្ញាធរទន្លេសាប បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ការងាររបស់អង្គភាពឲ្យមានប្រសិទ្ធភាព និងសាមគ្គីភាពផ្ទៃក្នុងរឹងមាំ ស្របតាមគោលការណ៍ណែនាំបន្ថែមពីថ្នាក់ដឹកនាំ រួមជាមួយការអនុវត្តសកម្មភាពប្រចាំថ្ងៃ និងការចែករំលែក ផ្សព្វផ្សាយនូវព័ត៌មាន របាយការណ៍ពាក់ព័ន្ធជាឯកសារទន់ និងរឹង (Hard and Soft) ដែលបានមកពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សា ការប្រឹក្សាយោបល់ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីទទួលយកមកពិនិត្យនូវចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមសម្រាប់កែលម្អ និងដោះស្រាយបន្តក្នុងដំណើរការការងារអង្គភាពសំដៅឆ្ពោះទៅរកភាពជោគជ័យប្រកបដោយសុខដុមនីយកម្ម។

### ទិសដៅទី២ ពង្រឹងការយល់ដឹងជាមូលដ្ឋាន អំពីការគ្រប់គ្រងតំបន់បឹងទន្លេសាប

ចាប់តាំងពីការបង្កើតអាជ្ញាធរទន្លេសាប សកម្មភាពនៃការប្រមូលចងក្រង និងវិភាគព័ត៌មានទិន្នន័យដែលបានមកពីការចុះសិក្សាស្រាវជ្រាវជាក់ស្តែងជាច្រើន ត្រូវបានកំណត់ជាសកម្មភាពយុទ្ធសាស្ត្រអាទិភាពនៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាពដើម្បីពង្រឹងពង្រីកដល់ការយល់ដឹងអំពីការគ្រប់គ្រងតំបន់បឹងទន្លេសាប។

ជាមួយនឹងសកម្មភាពនៃការពង្រឹងការយល់ដឹងជាមូលដ្ឋាន អាជ្ញាធរទន្លេសាប បានយកចិត្តទុកដាក់ក្នុងការវិភាគចងក្រងនូវរាល់ព័ត៌មានទិន្នន័យពាក់ព័ន្ធ រួមមាន៖(ក). **ស្ថានភាពសេដ្ឋកិច្ចសង្គម និងការគ្រប់គ្រងធនធានធម្មជាតិ** ដែលជាព័ត៌មានទិន្នន័យពាក់ព័ន្ធជាមួយនឹងស្ថានភាពសង្គម និងចំណេះដឹងលើការប្រើប្រាស់ជាមួយដំណើរការគ្រប់គ្រង អភិវឌ្ឍ ប្រសិទ្ធភាពការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ (ខ). **ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានធនធានធម្មជាតិ** ជាការសិក្សាពាក់ព័ន្ធជាមួយស្ថានភាពរបបជលសាស្ត្រ ធនធានទឹក (គុណភាព និងបរិមាណ) តំបន់ដីសើមកាកសំណល់ សក្តានុពលទេសចរណ៍តំបន់បឹងទន្លេសាប និងជីវចម្រុះធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាបដូចជា៖ ព្រៃលិចទឹក វារីសត្វ សិប្បីសត្វ ត្រី រួមទាំងការធ្វើចរាចរត្រី។ (គ). **អាជីវកម្មជលផល និងធនធានរ៉ែក្នុងតំបន់បឹងទន្លេសាប** ជាការសិក្សាពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឧបករណ៍នេសាទ ផលនេសាទជាលក្ខណៈគ្រួសារ និងលក្ខណៈអាជីវកម្មធំៗដែលស្ថិតតាមស្ទឹង វាលស្រែ អាងទឹក ប្រព័ន្ធជារាសាស្ត្រ ការសិក្សាផលចាប់តាមឡូត៍ដាយ និងការកែច្នៃផលនេសាទក្នុងតំបន់ជុំវិញបឹងទន្លេសាប រួមជាមួយការធ្វើអាជីវកម្មរ៉ែ។ (ឃ). **ការធ្វើកសិកម្ម ការប្រើប្រាស់ដី និងថ្នាំគីមី** ជាការសិក្សាស្រាវជ្រាវអំពីស្ថានភាពផលិតកម្មកសិកម្ម ការប្រើប្រាស់ដី និងថ្នាំគីមីកសិកម្មរបស់ប្រជាកសិករស្ថិតក្នុងតំបន់១ និងតំបន់២ក្រោមផ្លូវជាតិលេខ៥ និងលេខ៦ ជុំវិញតំបន់បឹងទន្លេសាប។

លទ្ធផលនៃការចុះសិក្សាស្រាវជ្រាវជាក់ស្តែង និងការធ្វើបច្ចុប្បន្នភាពព័ត៌មានទិន្នន័យដែលមានស្រាប់បានមកពីប្រភពពាក់ព័ន្ធនានា បានឆ្លុះបញ្ចាំងឲ្យឃើញពីរបកគំហើញក្នុងការប្រែប្រួលបរិយាកាសនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងដំណើរការនៃការគ្រប់គ្រងពីអ្នកពាក់ព័ន្ធដោយផ្ទាល់

និងដោយប្រយោលមកលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធរួមមានះ ធនធានជលផល របបជលសាស្រ្ត ធនធានទឹក ជីវសាស្រ្តចម្រុះ ការទ្រទ្រង់ជីវភាពរស់នៅ ការប្រើប្រាស់ដីធ្លី ការធ្វើអាជីវកម្ម កសិកម្ម ព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប ។ល។ ជារួមតាមការសិក្សា និងវិភាគបង្ហាញឲ្យឃើញពីភាពថយចុះ និងការគំរាមកំហែងឥតឈប់ឈរគួរឲ្យព្រួយបារម្ភលើធនធានដ៏កម្រក្នុងតំបន់បឹងទន្លេសាបនាពេលបច្ចុប្បន្ន និងពេលអនាគត ចំពោះសកម្មភាពអនាធិបតេយ្យដោយការ ធ្វើអាជីវកម្មហួសកម្រិតក្នុងការទាញយកអត្ថប្រយោជន៍ធនធានធម្មជាតិពីបឹងទន្លេសាប និងការទទួលរងនូវផលប៉ះពាល់ពីការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធតំបន់មេគង្គខាងលើ តំបន់ជុំវិញបឹងទន្លេសាប និងលើផ្ទៃបឹងទន្លេសាប។

បញ្ហាការគ្រប់គ្រងធនធានធម្មជាតិជាប់ទាក់ទងគ្នាទៅវិញទៅមក ហើយការប្រឈមមុខដាក់គ្នាតែងតែកើតមានឡើងជារឿយៗរវាងក្រុមដែលមានលទ្ធភាពប្រើប្រាស់ធនធានទីទៃពីគ្នា កម្រិតជំនាញក្រសួងស្ថាប័នខុសៗគ្នា និងកម្រិតចំណូលក៏មានភាពខុសពីគ្នាផងដែរ។ ជម្លោះនៅក្នុងតំបន់បឹងទន្លេសាបអាចត្រូវបានមហាជនមើលឃើញពីភាពមិនចុះសម្រុងគ្នារវាងទស្សនៈទូទៅផ្សេងៗគ្នា ដែលលើកឡើងដោយភាគីជម្លោះទាំងអស់នោះនៅក្នុងតំបន់បឹងទន្លេសាប។

ការប្រើប្រាស់ដី ព្រៃលិចទឹក នេសាទខុសច្បាប់ គឺជាឫសគល់នៃជម្លោះជាច្រើនលើធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប។ ការរុករានដីនៅក្នុងឋបនីយជីវមណ្ឌលបឹងទន្លេសាប បានធ្វើឲ្យដែនព្រៃលិចទឹកថយចុះដែលបណ្តាលមកពីការកែប្រែដីសម្រាប់ធ្វើកសិកម្ម។ ព្រៃលិចទឹកបម្រើឲ្យមុខងារប្រព័ន្ធអេកូឡូស៊ីមួយចំនួនដោយការពារច្រាំងទន្លេពីសំណឹកដោយសារទឹករលក ផ្តល់ទីជម្រកសម្រាប់មច្ឆជាតិ សត្វស្លាប និងសត្វដែលរស់នៅក្នុងព្រៃលិចទឹកជាច្រើនផ្សេងទៀត ជាមួយគ្នានឹងការផ្តល់នូវសេចក្តីត្រូវការចាំបាច់សម្រាប់មនុស្សលោកទូទៅជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលរស់នៅផ្ទាល់ក្នុងបឹងទន្លេសាប និងជុំវិញតំបន់បឹងទន្លេសាប។

ការធ្វើអាជីវកម្មហួសកម្រិត ដែលកើតមានឡើងពីបទល្មើសនេសាទ និងការនេសាទខុសច្បាប់ទៅលើធនធានធម្មជាតិនៅក្នុងបឹងទន្លេសាប គឺនៅតែកើតមានឡើងគំរាមគំហែងលើជីវចម្រុះ ត្រី សត្វល្មូន ធ្វើឲ្យមានការថយចុះជាលំដាប់នៃប្រភេទ បរិមាណ និងទំហំនៃធនធានធម្មជាតិសំខាន់ៗដែលចាប់បាន។ សម្ពាធនៃការនេសាទខុសច្បាប់នៅតែកើតមានឡើងមិនចេះឈប់ឈរ ទោះបីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលុបចោលឡូត៍នេសាទជុំវិញតំបន់បឹងទន្លេសាប ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផលក្នុងគោលបំណងតែមួយគត់ គឺធ្វើឲ្យសម្បត្តិធនធានធម្មជាតិមួយក្នុងចំណោមសម្បត្តិធម្មជាតិសំខាន់ៗបំផុតជាច្រើនទៀតសម្រាប់សេដ្ឋកិច្ចកម្ពុជា ហើយវាសំខាន់យ៉ាងខ្លាំងសម្រាប់ឋបនីយជីវមណ្ឌលបឹងទន្លេសាបក៏ដោយ។

### ទិសដៅទី៣ សម្របសម្រួល កសាងផែនការ និងការគ្រប់គ្រង

ការបន្តពង្រឹងពង្រីកតួនាទីភារកិច្ចបេសកកម្មស្នូល និងប្រសិទ្ធភាពការងារអំឡុងពេលនៃដំណើរការផែនការយុទ្ធសាស្រ្ត ២០១៦-២០២០ អាជ្ញាធរទន្លេសាប បានចូលរួមសម្របសម្រួលនូវការអនុវត្តការងារជាមួយបណ្តាក្រសួង/ស្ថាប័នជំនាញ និងគម្រោងភាពជាដៃគូតាមរយៈការដាក់ចេញនូវផែនការសកម្មភាព

ការងារប្រចាំឆ្នាំ ដោយមានការយកចិត្តទុកដាក់គាំទ្រដល់កិច្ចការងារ និងអភិវឌ្ឍន៍បរិស្ថានធនធានធម្មជាតិ និងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនោះ ក៏ចូលរួមផ្តួចផ្តើមគំនិតក្នុងការចែករំលែកការយល់ដឹង បទពិសោធន៍ និងផ្សព្វផ្សាយពីលទ្ធផលរបកគំហើញដែលបានពីការសិក្សាស្រាវជ្រាវ ស្វែងយល់ នឹងប្រមូលចងក្រងធ្វើបច្ចុប្បន្នភាពរាល់ព័ត៌មានទិន្នន័យទៅតាមស្ថានភាពទីតាំងជាក់ស្តែង ដែលបាន និងកំពុងកើតឡើងក្នុងពេលបច្ចុប្បន្ន និងពេលអនាគតទៅលើការគ្រប់គ្រងធនធានដ៏កម្រនៅតំបន់បឹងទន្លេសាប ជាពិសេសសម្របសម្រួលលើកកម្ពស់ដល់ការយល់ដឹងអំពីការចូលរួមផ្នែកច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធនៃដំណើរការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់នៅក្នុងច្បាប់ ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញចាប់តាំងពីឆ្នាំ២០០៧ និងបានចែករំលែកផ្សព្វផ្សាយយល់ដឹងអំពីព័ត៌មានទិន្នន័យផ្សារភ្ជាប់ឯកសារបទដ្ឋានគតិយុត្តនៃដំណើរការអភិវឌ្ឍ និងកិច្ចការពារបរិស្ថាន ធនធានធម្មជាតិប្រកបដោយចីរភាពនៅតំបន់បឹងទន្លេសាប ដែលក្រុមមន្ត្រីជំនាញពាក់ព័ន្ធនៃនាយកដ្ឋានជំនាញទាំង៤ ក្រោមឱវាទបាន និងកំពុងប្រមែប្រមូលចងក្រងទុកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់។

ផ្សារភ្ជាប់កិច្ចការសម្របសម្រួលនេះផងដែរ ក៏បានធ្វើការពង្រឹងនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើរាល់ព័ត៌មាន/ទិន្នន័យគម្រោងដែល បាន និងកំពុងអនុវត្តន៍ និងមានផែនការអនុវត្តដែលក្នុងនោះមានគម្រោងគាំទ្រថវិកាដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលតាមរយៈគម្រោងខ្នាតតូចៗតាមសហគមន៍មូលដ្ឋានជុំវិញតំបន់បឹងទន្លេសាបដូចជា៖ ការទាញចេញពីប្រភពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងសប្បុរសជនផ្សេងៗ ដោយបានធ្វើការពិនិត្យលើឯកសារផែនការគម្រោងមុននឹងចាប់ផ្តើមដែលបានឆ្លុះបញ្ចាំងពីការចូលរួមលើកកម្ពស់ដល់កិច្ចការពារបរិស្ថានធនធានធម្មជាតិ និងកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតំបន់បឹងទន្លេសាប។ ការធ្វើបច្ចុប្បន្នភាពចំនួនគម្រោងមកដល់ចុងឆ្នាំ ២០២០ នេះ សរុបប្រមាណ ១៨៦៥ គម្រោង ក្នុងនោះគម្រោងបានបញ្ចប់ ចំនួន ១២០០ និងកំពុងអនុវត្តន៍ចំនួន ៦៦៥ ជាមួយនីតិវិធីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងដែលកំពុងអនុវត្តន៍ និងគ្រោងអនុវត្តបន្តទៀត។ មន្ត្រីជំនាញក្រោមឱវាទអាជ្ញាធរទន្លេសាបបាន និងកំពុងខិតខំប្រឹងប្រែងសម្របសម្រួលប្រាស្រ័យទាក់ទង និងស្នើសុំកិច្ចសហការជាមួយបណ្តាក្រសួង/ស្ថាប័ន និងដៃគូនានាដែលជាភាគីដឹកនាំគម្រោងផ្ទាល់ដើម្បីរៀបចំឲ្យមានយន្តការ នីតិវិធី/វិធីសាស្ត្រ រួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់គម្រោងនៅតំបន់បឹងទន្លេសាបក្នុងគោលបំណង បញ្ចៀស នូវការត្រួតជាន់គ្នាក្នុងការអនុវត្ត និងប្រសិទ្ធភាពបន្ទាប់ពីគម្រោងបញ្ចប់។ ដោយកម្រិតការយល់ដឹងរបស់មន្ត្រីដែលទទួលខុសត្រូវនៅមានកម្រិតក្នុងជំនាញតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី/គម្រោង អាជ្ញាធរទន្លេសាបក៏ជំរុញឲ្យមានការយកចិត្តទុកដាក់ដល់ការពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស ក្នុងនោះបានជំរុញឲ្យមានកម្មវិធីបណ្តុះបណ្តាលជំនាញតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីគម្រោងប្រចាំឆ្នាំដល់មន្ត្រីរាជការពាក់ព័ន្ធបន្ថែមទៀត។

តាមរយៈលទ្ធផលនៃការចុះអនុវត្តសកម្មភាពការងារសិក្សាស្រាវជ្រាវកន្លងមក អាជ្ញាធរទន្លេសាបបាន និងកំពុងប្រឹងប្រែងធ្វើការវិភាគដោយយកចិត្តទុកដាក់ជាមួយការរៀបចំបញ្ចូលនូវរបាយការណ៍បច្ចេកទេសអំពីលទ្ធផលស្រាវជ្រាវទៅតាមគម្រោងសកម្មភាពនីមួយៗ។ តាមរយៈក្រុមការងារបច្ចេកទេសនីមួយៗដែលដឹកនាំដោយ ឯកឧត្តមអគ្គលេខាធិការត្រូវបានបង្កើតឡើងជាសេនាធិការឲ្យដល់ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលផ្តុំរាល់របាយការណ៍ពាក់ព័ន្ធសកម្មភាពស្រាវជ្រាវដើម្បីចងក្រងឲ្យទៅជាកម្រងរបាយការណ៍បច្ចេកទេសគ្រប់សកម្មភាពស្រាវជ្រាវ និងវិភាគឯកសារបច្ចេកទេសដាច់ដោយឡែកពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាបសម្រាប់ជាមូលដ្ឋានរៀបចំនូវក្រុបខណ្ឌគោលនយោបាយយុទ្ធសាស្រ្ត ផែនការ និងគម្រោងសកម្មភាព/កម្មវិធីក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។ ជាក់ស្តែងការដាក់ឲ្យប្រើប្រាស់ និងស្វែងយល់នូវរាល់ឯកសារកម្រងរបាយការណ៍បច្ចេកទេសសិក្សាស្រាវជ្រាវអំពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់បឹងទន្លេសាប រួមជាមួយទស្សនាវដ្តី សកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប និងកម្រងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ។

### ទិសដៅទី៤ ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ

ការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងផ្សព្វផ្សាយឲ្យបានយល់ដឹងពីសារៈសំខាន់មុខងាររបស់តំបន់បឹងទន្លេសាប ជាពិសេសការបញ្ជ្រាបរាល់ព័ត៌មានឲ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធអំពីសកម្មភាពការងារ និងវឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប ក្នុងស្មារតីទទួលខុសត្រូវចូលរួមលើកកម្ពស់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់កិច្ចការពារបរិស្ថានធនធានធម្មជាតិ តំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។ ជាក់ស្តែងមន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាបបានខិតខំប្រឹងប្រែងយ៉ាងសកម្មដោយប្រើប្រាស់រាល់ចំណេះដឹង បទពិសោធន៍ និងការយល់ដឹងចេញពីលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវតាមទីតាំងផ្ទាល់ធ្វើជាមូលដ្ឋានក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធដែលជាក្រុមគោលដៅក្នុងការបង្កើតជាបណ្តាញដៃគូសន្ទនាការងារក្នុងអង្គប្រជុំ សិក្ខាសាលា វេទិកានានា ទាំងកម្រិតថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

ការកសាងអភិវឌ្ឍសមត្ថភាពអ្នកពាក់ព័ន្ធ បើទោះជាអាជ្ញាធរទន្លេសាបមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ទាំងថវិកា និងធនធានមនុស្សប្រកបដោយសមត្ថភាពក្នុងការចែករំលែក និងធ្វើការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល ឬទស្សនកិច្ចសិក្សាស្វែងយល់ការងារទៅវិញទៅមកតាមតំបន់ ឬទីតាំងជាក់ស្តែងឲ្យបានទូលំទូលាយជាមួយបណ្តាភាគីពាក់ព័ន្ធក៏ដោយ ក៏អាជ្ញាធរទន្លេសាប នៅតែបន្តការយកចិត្តទុកដាក់ចំពោះបញ្ហាកង្វះខាតនេះជាអាទិភាពនៅក្នុងផែនការសកម្មភាពជាប្រចាំដើម្បីកៀរគរជំនួយ និងបង្កើនសមត្ថភាពធនធានមនុស្ស។ ពាក់ព័ន្ធបញ្ហាកសាងសមត្ថភាពនេះដែរអាជ្ញាធរទន្លេសាប បាន និងកំពុងតែពង្រឹងពង្រីកចំណេះដឹងដល់មន្ត្រីរាជការរបស់ខ្លួនតាមរយៈវគ្គកសាងសមត្ថភាពជាច្រើនដោយអនុលោមតាមផែនការសកម្មភាពប្រចាំឆ្នាំ និងផ្សារភ្ជាប់ជាមួយលទ្ធផលរបកគំហើញនៃការចុះជាក់ស្តែង។ ក្នុងនោះក៏បានប្រឹងប្រែងយកចិត្តទុកដាក់ដោយប្រើប្រាស់នូវសកម្មភាព

ការងាររួមជាមួយស្ថូចនាករសំខាន់ៗមួយចំនួនដើម្បីចែករំលែកផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ រាល់ធាតុសំខាន់ៗនៃដំណើរការគ្រប់គ្រងបរិស្ថានធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប វឌ្ឍនភាពការងារ និងសកម្មភាពការងារអង្គភាពទាំងក្នុងកម្រិតជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងថ្នាក់តំបន់ក្នុងកិច្ចប្រជុំសិក្ខាសាលា រួមជាមួយការចែករំលែកតាមបណ្តាញសង្គម និងគេហទំព័ររបស់អាជ្ញាធរទន្លេសាប។ល។

### ទិសដៅទី៥ ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាបប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព

ការពង្រឹងសមត្ថភាពការងារ និងតួនាទីភារកិច្ចអាជ្ញាធរទន្លេសាបដូចបានកំណត់ក្នុងព្រះរាជក្រឹត្យ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាពិសេសការដាក់ចេញនូវរាល់គោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះការចូលរួមគិតគូរឲ្យបានស៊ីជម្រៅលើតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព។ តាមរយៈនៃការដាក់ចេញនូវទិសដៅ និងសកម្មភាពក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប និងជំរុញប្រសិទ្ធភាពការអនុវត្តដោយប្រើប្រាស់សូចនាករសំខាន់ៗ និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃទៅលើប្រសិទ្ធភាពការងារ លទ្ធផលនៃការប្រតិបត្តិការងារប្រចាំឆ្នាំ ដោយជំរុញការអនុវត្តសកម្មភាពដែលបានអនុម័តដាក់បញ្ចូលក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងនោះក៏បានកំណត់ឲ្យមានរបាយការណ៍ជាប្រចាំតាមការចុះអនុវត្តតាមសកម្មភាពនីមួយៗក្នុងផែនការសកម្មភាពការងារដូចជា៖ របាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍តាមដានការអនុវត្តផែនការសកម្មភាពពាក់កណ្តាលអាណត្តិដើម្បីពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាព និងធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹងការអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំឲ្យកាន់តែមានប្រសិទ្ធភាព។

ការពង្រឹងប្រសិទ្ធភាពការងារដើម្បីឈានទៅសម្រេចទិសដៅយុទ្ធសាស្ត្រតាមការរំពឹងទុក នៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ អាជ្ញាធរទន្លេសាបតែងតែប្រើប្រាស់បទពិសោធន៍អនុវត្តការងារជាប្រចាំក្នុងការពិនិត្យទៅលើចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមនានា ដែលបាន និងកំពុងកើតមានឡើងតាមសកម្មភាព វឌ្ឍនភាពការងារ ការប្រជុំពិភាក្សាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីកែតម្រូវសកម្មភាពឲ្យមានសង្គតិភាពជាមួយសូចនាករ និងទិសដៅយុទ្ធសាស្ត្រ។ ជាក់ស្តែង អាជ្ញាធរទន្លេសាប បាន និងកំពុងប្រមូលផ្តុំការប្រឹក្សាយោបល់ និងពិនិត្យលើឯកសាររបាយការណ៍លទ្ធផលការងារសកម្មភាពពាក់ព័ន្ធនៅក្នុងគម្រោងសកម្មភាពការងារផែនការប្រចាំឆ្នាំនីមួយៗ ដើម្បីធ្វើបច្ចុប្បន្នភាព រៀបចំតារាងម៉ាទ្រិកសកម្មភាពការងារឈានទៅដល់ការរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ ដើម្បីបន្តនៅក្នុងឆ្នាំបន្តបន្ទាប់ដែលជាតួនាទី ភារកិច្ច និងការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការដ្ឋានចំពោះ មុខថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប។

ក្នុងការដាក់ចេញនូវទស្សនវិស័យ ទិសដៅយុទ្ធសាស្ត្រ និងកម្មវិធី/គម្រោងសកម្មភាពការងារប្រទាក់ក្រឡាគ្នារបស់អង្គភាព អាជ្ញាធរទន្លេសាប ក៏បានប្រើប្រាស់ជាមូលដ្ឋានពង្រឹងពង្រីកបណ្តាញទំនាក់ទំនងជាពិសេសការកៀរគរថវិកា និងជំនួយបច្ចេកទេសទាំងផ្នែករដ្ឋាភិបាលកម្ពុជា និងដៃគូភាគីពាក់ព័ន្ធដោយបានឆ្លុះបញ្ចាំងតាមរយៈការចចារ កិច្ចប្រជុំ ការពិភាក្សា សិក្ខាសាលាចែករំលែកការយល់ដឹង

បទពិសោធន៍ក្នុងគោលដៅពង្រីកឥទ្ធិពល និងពង្រឹងប្រសិទ្ធភាពការងារអង្គភាពប្រកបដោយចីរភាព។ បច្ចុប្បន្នក្រសួង/ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា បាន និងកំពុងមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយសកម្មភាពការងារ លទ្ធផលរបកគំហើញនៃការសិក្សាស្រាវជ្រាវ និងវឌ្ឍនភាពការងាររបស់អាជ្ញាធរទន្លេសាប ដែលមានជាបន្តបន្ទាប់ក្នុងការយកទៅពិចារណាដើម្បីពិនិត្យលទ្ធភាពគាំទ្រដល់ដំណើរការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាប។ អាជ្ញាធរទន្លេសាប បាន និងកំពុងផ្សារភ្ជាប់ជាមួយបណ្តាញអង្គការអាងទន្លេតាមរយៈគម្រោងកិច្ចសហប្រតិបត្តិការរួមទាំងទស្សនកិច្ចសិក្សាផ្លាស់ប្តូរក្នុងវេទិកា និងសន្និសីទក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិដូចជា៖ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន (ភ្នាក់ងារទឹកបារាំង) គម្រោងការរៀបចំបង្កើតវេទិកាអភិរក្សបរិស្ថានធនធានធម្មជាតិបឹងទន្លេសាប គម្រោងកិច្ចសហប្រតិបត្តិការគ្រប់គ្រងធនធានទឹកចម្រុះឆ្លងដែនរវាងបឹងទន្លេសាប(កម្ពុជា)និងអាងសុងក្លា(ថៃ)កិច្ចសហការផ្លាស់ប្តូរចែករំលែកការយល់ដឹង International Lake Environment Committee Foundation (Japan) និងគម្រោង Fisher Catch Monitoring in the Provinces around Tonle Sap Lake, Cambodia (Mekong River Commission) និងកំពុងពិចារណាអត្ថប្រយោជន៍ក្នុងការចូលជាសមាជិក Global Water Partnership។

ការយកចិត្តទុកដាក់ជំរុញប្រសិទ្ធភាពការងារបច្ចេកទេស និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការកៀរគរជំនួយពីដៃគូអភិវឌ្ឍន៍នានា អាជ្ញាធរទន្លេសាបក៏បានខិតខំប្រឹងប្រែងប្រតិបត្តិការងារប្រចាំថ្ងៃនៅក្នុងអង្គភាពដើម្បីជំរុញប្រសិទ្ធភាពដំណើរការរៀបចំតាមដានផែនការសកម្មភាព និងការសម្របសម្រួលបញ្ជ្រាបផែនការថវិកាអង្គភាពចូលក្នុងថវិកាកម្មវិធីប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ ក្នុងនោះការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកបានយកចិត្តទុកដាក់លើកទឹកចិត្តមន្ត្រីរាជការ មន្ត្រីកិច្ចសន្យា និងថ្នាក់ដឹកនាំក្រោមឱវាទ និងការកសាងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធទទួលបាននូវការបណ្តុះបណ្តាល ទាំងនៅក្នុង និងក្រៅប្រទេស។

ក្នុងការជំរុញប្រសិទ្ធភាពនៃដំណើរការរៀបចំតាមដានផែនការយុទ្ធសាស្ត្រ បានបង្កើតឲ្យមានការប្រជុំពិគ្រោះយោបល់តាមដាន ដើម្បីពិនិត្យពីវឌ្ឍនភាពការងារទាំងចំណុចខ្សោយ ចំណុចខ្លាំង និងបញ្ហាប្រឈមក្នុងការវាយតម្លៃពីលទ្ធផលសម្រេចបាន សម្រាប់រៀបចំបច្ចុប្បន្នភាពសកម្មភាពការងារ និងផែនការសកម្មភាពជាបន្តបន្ទាប់។ ផ្អែកលើមូលដ្ឋានសកម្មភាពការងារ និងតួនាទីភារកិច្ចទទួលខុសត្រូវក្នុងបទប្បញ្ញត្តិ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារ បានប្រើប្រាស់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីសមាហរណកម្មចូលក្នុងកម្មវិធីប្រចាំឆ្នាំដែលធ្វើឲ្យកញ្ចប់ថវិកាគ្រោងចំណាយបច្ចុប្បន្នបានកើនឡើងសរុបចំនួន ៤,៣០០លានរៀលក្នុង១ឆ្នាំ។

ការងារគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកអាជ្ញាធរទន្លេសាប បានពង្រឹងការយកចិត្តទុកដាក់ខ្ពស់ និងបានធ្វើការណែនាំជាប្រចាំដល់មន្ត្រីរាជការក្រោមឱវាទឲ្យទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល ដើម្បីសម្រួលឲ្យដំណើរការការងារប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាពដូចជា៖ ការគ្រប់គ្រងចរន្តលិខិតចេញ-ចូល គឺបានធ្វើការពិនិត្យរាល់ខ្លឹមសារ អត្ថន័យលិខិតបទដ្ឋានគតិយុត្តនានា និងសម្របសម្រួលលិខិតចេញ-ចូលពាក់ព័ន្ធក្នុង

អង្គភាព។ ក្នុងនោះដែរបានជំរុញឲ្យមានការយកចិត្តទុកដាក់ទៅលើការថែទាំ ជួសជុលនូវទ្រព្យសម្បត្តិរដ្ឋ និងសម្របសម្រួលដល់ការផ្គត់ផ្គង់សម្ភារបរិក្ខារជាលក្ខណៈរដ្ឋបាល និងលក្ខណៈបច្ចេកទេសជូនដល់ថ្នាក់ដឹកនាំ និងមន្រ្តីរាជការក្រោមឱវាទ ដើម្បីឲ្យដំណើរការនៃការងារមានប្រសិទ្ធភាព។ ក្នុងដំណើរការសកម្មភាពគ្រប់គ្រងបុគ្គលិក គឺបានផ្តល់នូវសេចក្តីណែនាំ និងក្រើនរំលឹកជាបន្តបន្ទាប់ចំពោះការពង្រឹងតួនាទីភារកិច្ចក្នុងនាមជាមន្ត្រីរាជការដែលកំពុងបម្រើការងារនៅក្នុងអង្គភាពនៃអាជ្ញាធរទន្លេសាប ដោយអនុលោមគោរពតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

ការបំពេញការងារស្នូលអង្គភាពរួមជាមួយការចុះអនុវត្តការងារជាក់ស្តែង បើទោះបីជាចំនួនមន្ត្រីដែលកំពុងបម្រើការងារបច្ចុប្បន្នមានការយល់ដឹងនៅមានកម្រិតក៏ដោយ ក៏អាជ្ញាធរទន្លេសាបបានប្រឹងប្រែងយកចិត្តទុកដាក់លើមន្ត្រីរាជការ ដោយមានការលើកទឹកចិត្តជូនដល់មន្ត្រីរាជការដូចជា តំឡើងតួនាទី តំឡើងឋានន្តរស័ក្តិ តំឡើងកាំប្រាក់ និងស្នើសុំផ្តល់គ្រឿងឥស្សរិយយសជាដើម។ ក្នុងនោះដែរ ក៏បានជំរុញលើកកម្ពស់ដល់ការពង្រឹងការយល់ដឹងដល់មន្ត្រីរាជការបន្ថែមដោយបានគិតគូរដល់ការបង្កើនសមត្ថភាព និងអភិវឌ្ឍចំណេះដឹងបន្ថែមទៀតដល់មន្ត្រីរាជការ តាមរយៈការបញ្ជូនមន្ត្រីឲ្យទៅចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស។

## ២.២- បញ្ហាប្រឈម

ជាមួយវឌ្ឍនភាពការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ ខាងលើ អាជ្ញាធរទន្លេសាប ក៏បានជួបប្រទះនូវចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួន រួមមាន៖

- ការចូលរួមគាំទ្រ និងសហការនៅមានកម្រិត ពីបណ្តាក្រសួង/ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់សហគមន៍មូលដ្ឋាន និងថ្នាក់តំបន់
- ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងធនធានមនុស្សមិនទាន់អាចឆ្លើយតបបានពេញលេញទៅតាមសេចក្តីត្រូវការនៅឡើយជាពិសេសធនធានមនុស្សទៅតាមជំនាញនីមួយៗ
- ចំនួនមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធការងាររបស់នាយកដ្ឋាននីមួយៗនៅមានចំនួនតិច ដែលមិនទាន់ឆ្លើយតបនឹងទំហំការងារបានពេញលេញនៅឡើយ
- ការផ្តល់អាទិភាព និងការចូលរួមក្នុងការអនុវត្តការងាររបស់មន្ត្រីរាជការនៅមានកម្រិត
- ចំនួនមន្ត្រីរាជការជាស្ត្រីនៅមានកម្រិត
- ការប្រែប្រួលអាកាសធាតុ ពិសេសលើការប្រែប្រួលរបបជលសាស្ត្រដែលប៉ះពាល់ដល់សកម្មភាពស្រាវជ្រាវមួយចំនួនមិនអាចអនុវត្តន៍បានពេញលេញ
- ការកើតឡើង និងរីករាលដាលនៃជម្ងឺកូវីដ-១៩ បានជះឥទ្ធិពលដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ (បន្ថយសកម្មភាពចុះអនុវត្តន៍ការងារប្រចាំថ្ងៃមួយចំនួន)
- ការអនុវត្តការងាររដ្ឋបាល និងបច្ចេកទេស គឺត្រូវពឹងផ្អែកលើសម្ភារបច្ចេកទេសទំនើបកម្មក៏ប៉ុន្តែការប្រើប្រាស់នូវកញ្ចប់ថវិកាសម្រាប់ការចំណាយ និងដំណើរការសកម្មភាពនៅមានកម្រិត

- ការគ្រប់គ្រងទិន្នន័យលើការសិក្សាស្រាវជ្រាវតាមដាន និងឯកសារផ្សេងៗនាពេលកន្លងមកពុំទាន់មានការប្រមូលផ្តុំជាប្រព័ន្ធទិន្នន័យរួមសម្រាប់ប្រើប្រាស់នៅអាជ្ញាធរទន្លេសាប ក៏ដូចជាការផ្សព្វផ្សាយពុំទាន់មានភាពទូលំទូលាយនៅឡើយ
- ការរៀបចំវគ្គបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី គឺពុំបានឆ្លើយតបទាំងស្រុងទៅតាមតម្រូវការជាក់ស្តែងរបស់នាយកដ្ឋានជំនាញនីមួយៗ ព្រមទាំងអគ្គលេខាធិការដ្ឋានទាំងមូល
- ការចូលរួមសិក្ខាសាលា សន្និសីទក្នុង និងក្រៅប្រទេសពុំបានឆ្លើយតបពេញលេញទៅតាមតម្រូវការរបស់ស្ថាប័ននៅឡើយ ក៏ដូចជាការផ្សព្វផ្សាយនូវលទ្ធផលនៃកិច្ចប្រជុំ។

រាល់សមិទ្ធផល បញ្ហាប្រឈម និងចំណុចខ្វះខាតនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២០ គឺជាធាតុចូលមួយដ៏សំខាន់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥។

# ផ្នែកទី៣

# ផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២១-២០២៥

ការកំណត់នូវចក្ខុវិស័យ នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបគឺស្របជាមួយអាណត្តិ និងតួនាទីភារកិច្ចដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប។

ជាក់ស្តែងបច្ចុប្បន្នតំបន់បឹងទន្លេសាបត្រូវបានទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងតាមរយៈកត្តាមនុស្ស និងកត្តាប្រែប្រួលអាកាសធាតុ ដែលតម្រូវឲ្យអាជ្ញាធរទន្លេសាបចាំបាច់ពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រទំនើបដើម្បីកំណត់រាល់មូលហេតុបញ្ហាប្រឈមនិងដំណោះស្រាយផ្សេងៗនៅក្នុងតំបន់បឹងទន្លេសាប។

យោងលើអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិបណ្ឌិត **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាបសំដៅឲ្យអាជ្ញាធរទន្លេសាបពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព។

ហេតុដូចនេះ សម្រាប់នីតិកាលទី៦ និងជាលើកទី២ នៃការរៀបចំផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាបបានកំណត់យកចក្ខុវិស័យផ្តោតលើការសិក្សាស្រាវជ្រាវអមដោយ បេសកកម្ម គោលដៅយុទ្ធសាស្ត្រ ទិសដៅយុទ្ធសាស្ត្រ និងសកម្មភាពយុទ្ធសាស្ត្រដែលជាគ្រោងឆ្អឹងដ៏រឹងមាំ និងប្រទាក់ក្រឡាគ្នា រួមមានជាអាទិ៍៖

ដ្យាក្រាមទី២ គំនូសបំព្រួញរចនាសម្ព័ន្ធចក្ខុវិស័យ បេសកកម្ម និងសសរស្តម្ភ



## ៣.១- ចក្ខុវិស័យ និងបេសកកម្ម

៣.១.១. ចក្ខុវិស័យ ក្របខណ្ឌផែនការយុទ្ធសាស្ត្រ សម្រាប់អាជ្ញាធរទន្លេសាប បង្កើតឡើងដោយផ្អែកលើតួនាទី ភារកិច្ច ទស្សនវិស័យ និងបេសកកម្ម ដែលរាជរដ្ឋាភិបាលបានកំណត់ " **អាជ្ញាធរទន្លេសាបជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បឹងទន្លេសាបប្រកបដោយចីរភាព** " ។

៣.១.២. បេសកកម្ម ដើម្បីសម្រេចបាននូវចក្ខុវិស័យច្បាស់លាស់ខាងលើ **បេសកកម្មចំនួន៣** ត្រូវបានកំណត់ដូចខាងក្រោម៖

(១) ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព

(២) សម្របសម្រួល និងប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិនៃតំបន់បឹងទន្លេសាប

(៣) ពង្រឹងធនធានមនុស្ស មូលដ្ឋានទិន្នន័យ និងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ។

## ៣.២- គោលដៅយុទ្ធសាស្ត្រ និងគោលបំណង

### ៣.២.១. គោលដៅយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះមាន **គោលដៅយុទ្ធសាស្ត្រចំនួន៤** គាំទ្រដល់បេសកកម្មខាងលើរួមមាន៖

១- ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

២- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា

៣- លើកកម្ពស់ប្រសិទ្ធភាពនៃការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍

៤- ពង្រឹងការគ្រប់គ្រងអង្គភាព/ស្ថាប័ន និងមូលដ្ឋានចំណេះដឹងលើការសិក្សាស្រាវជ្រាវ។

### ៣.២.២. គោលបំណង

ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងរួម គឺពង្រឹងការសិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាបប្រកបដោយចីរភាព រវាងអាជ្ញាធរទន្លេសាបជាមួយភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាប។

## ៣.៣- បាវចនា និងរចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប

### ៣.៣.១. បាវចនា

ឯកឧត្តមកិត្តិបណ្ឌិត **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប សម្រាប់នីតិកាលទី៦ នេះ បានកំណត់យកនូវបាវចនាចំនួន៣ ដូចខាងក្រោម៖

១. ជាស្ថាប័នថ្នាក់ជាតិមួយក្នុងការសិក្សាស្រាវជ្រាវតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

២. ជាស្ថាប័នគ្រប់គ្រងទិន្នន័យ ព័ត៌មាន និងឯកសារស្រាវជ្រាវនៃតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៣. ការពារផលប្រយោជន៍មន្ត្រីរាជការ និងសុខដុមនីយកម្ម។

## ៣.៣.២. រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប

អាជ្ញាធរទន្លេសាប ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ អមដោយទីប្រឹក្សា និងជំនួយការមួយចំនួនតាមការចាំបាច់ និងមានអគ្គលេខាធិការដ្ឋានជាសេនាធិការផ្ទាល់ដើម្បីចាត់ចែងការងារទូទៅប្រចាំថ្ងៃ និងមាននាយកដ្ឋានក្រោមឱវាទចំនួន៤ រួមមាន៖

១. នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

២. នាយកដ្ឋានធនធានធម្មជាតិ

៣. នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស

៤. នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ។

### ដ្យាក្រាមទី៣ រចនាសម្ព័ន្ធរបស់អាជ្ញាធរទន្លេសាប



## ៣.៤- ទិសដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រដែលជាលទ្ធផលរំពឹងទុកទាំង៤ខាងលើ អាជ្ញាធរទន្លេសាប បានកំណត់នូវទិសដៅយុទ្ធសាស្ត្រចំនួន១០ ដែលមានជាអាទិ៍៖

១- ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីស្តែមតំបន់បឹងទន្លេសាប
២- ពង្រឹងប្រសិទ្ធភាព នៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងការតាមដានត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត
៣- ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់លើអេកូស៊ីស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច
៤- ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប
៥- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា
៦- ជំរុញប្រសិទ្ធភាពយន្តការសម្របសម្រួល និងប្រឹក្សាយោបល់
៧- លើកកម្ពស់ប្រសិទ្ធភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍
៨- លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងដំណើរការស្ថាប័នប្រកបដោយចីរភាព
៩- អភិវឌ្ឍន៍គោលនយោបាយយុទ្ធសាស្ត្រ និងកសាងផែនការសម្រាប់តំបន់បឹងទន្លេសាប
១០-ពង្រឹងសមត្ថភាពមន្ត្រីរាជការលើការសិក្សាស្រាវជ្រាវ តាមដានលើប្រធានបទនីមួយៗតាមគោលដៅរបស់អាជ្ញាធរទន្លេសាប។

## ៣.៥- សកម្មភាពយុទ្ធសាស្ត្រ (សកម្មភាពគន្លឹះ)

ដើម្បីជាគ្រឹះក្នុងការសម្រេចតាមចក្ខុវិស័យ បេសកកម្ម គោលដៅ ទិសដៅយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រនេះ សកម្មភាពយុទ្ធសាស្ត្រដែលជាកត្តាគន្លឹះ និងមានភាពប្រទាក់ក្រឡាគ្នាចំនួន២៧ សកម្មភាពគន្លឹះត្រូវបានកំណត់ដែលមានជាអាទិ៍៖

### ៣.៥.១. ពង្រឹងការសិក្សាស្រាវជ្រាវតាមបែបបទវិទ្យាសាស្ត្រជាមូលដ្ឋានក្នុងតំបន់បឹងទន្លេសាប

៣.៥.១.១. ជំរុញប្រសិទ្ធភាព និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវតាមដានលើអេកូស៊ីស្តែមតំបន់បឹងទន្លេសាប

១. ពិនិត្យឡើងវិញនូវសកម្មភាពក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ
២. ធ្វើការកំណត់ដែនវិសាលភាពដែលត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ
៣. សិក្សាស្រាវជ្រាវ និងវាយតម្លៃលើបច្ចុប្បន្នភាពធនធានធម្មជាតិតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ

៣.៥.១.២. ពង្រឹងប្រសិទ្ធភាពនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍព្រមទាំងការតាមដាន ត្រួតពិនិត្យសកម្មភាពដែលបាន និងកំពុងអនុវត្ត

១. តាមដានត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍ដែលមានស្រាប់ និងកំពុងអនុវត្តក្នុងតំបន់បឹងទន្លេសាប

២. កំណត់តម្រូវការជាមូលដ្ឋាន និងតាមដានពិនិត្យជាប្រចាំរាល់បញ្ហាដែលជួបប្រទះនៅតាមទីតាំងក្នុងតំបន់២ តំបន់៣ ជុំវិញបឹងទន្លេសាប

៣.៥.១.៣. ពង្រឹងការតាមដានជាសកម្មលើផលប៉ះពាល់នៃអេកូស៊ីស្តែម និងសម្របសម្រួលតាមការប្រែប្រួលអាកាសធាតុតំបន់បឹងទន្លេសាបទាំងលើធនធានធម្មជាតិ ទាំងលើវិស័យសង្គម/សេដ្ឋកិច្ច

១. សិក្សាតាមដានលើរបបជលសាស្ត្រ គុណភាពទឹក ព្រៃលិចទឹក ជីវចម្រុះ (ធនធានជលផល ប្រភេទ Flora and Fauna តាមទីតាំង និងរដូវកាល) សេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជនដែលមានភាពទំនាក់ទំនងនឹងសម្ពាធនៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ

២. ពង្រឹងការសិក្សាតាមដានប្រភេទព្រៃលិចទឹកតំបន់៣ និងអធិការកិច្ចដែនអភិរក្សព្រៃលិចទឹកតំបន់៣

## ៣.៥.២. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិទ្យា

៣.៥.២.១. ពង្រឹងប្រសិទ្ធភាព និងការរៀបចំគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់អាជ្ញាធរទន្លេសាប

១. ជំរុញប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានវិទ្យាអាជ្ញាធរទន្លេសាប

២. រៀបចំកសាងផលិតរបាយការណ៍ ស្តីពីស្ថានភាពបឹងទន្លេសាប

៣. ផលិតរូបភាពផែនទី/រូបថតលើអាកាស និងធ្វើបច្ចុប្បន្នភាពនៃតំបន់បឹងទន្លេសាប។

៣.៥.២.២. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការគ្រប់គ្រងលើការចែករំលែកព័ត៌មានវិទ្យា

